BBI0094

# សម្ភាសន៍ជាមួយឈ្មោះ កាន់ ឯម ភេទស្រី អាយុ៥២ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម«កម្មករ»

## រស់នៅពេជ្រចិន្តា ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។

## ថ្ងៃទី២១ខែមិនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០០:៤២:២៨

## ២៧ទំព័រ

វណ្ណៈ ចឹងថ្ងៃហ្នឹងថ្ងៃទី២១ ខែមិនា ឆ្នាំ២០១១ ចឹងជាដំបូងខ្ញុំចង់ណែនាំខ្លួនថាខ្ញុំឈ្មោះ សុខ វណ្ណៈ ខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានទីតាំងនៅភ្នំពេញណាមីង ។

ឯមៈ ចាស ។

វណ្ណៈ ហើយខ្ញុំបានមកដល់ភូមិស្រុកនេះ ក៏ដោយសារថាខ្ញុំចង់ដឹងរឿងរ៉ាវដែលបងប្អូនរត់មកឆ្លងកាត់វេទនាយ៉ាងម៉េចខ្លះ ហើយបានមករស់នៅកន្លែងនេះសម័យតស៊ូរំដោះជាមួយយួនទៀត ។

ឯមៈ ចាស ។

វណ្ណៈ ហើយយើងមានរឿងរ៉ាវជាច្រើនទៀត ដែលត្រូវចងក្រងជាឯកសារទុកសម្រាប់ក្មេងជំនាន់ក្រោយបានដឹងបានឮដែលណាមីងណា ។

ឯមៈ ចាស ។

វណ្ណៈ ឧបមាថាប្អូនដប់ម្ភៃសាមសិបឆ្នាំទៅមុខទៀត យើងស្លាប់បាត់ហើយយើងអត់មានប្រវត្តិហ្នឹងប្រាប់ក្មេងៗទេ ។

ឯមៈ ចាស ។

វណ្ណៈ ចឹងបើយើងសរសេរចងក្រងទៅយើងក្មេងៗបានដឹងថា កាលពីឆ្នាំនេះៗកាលជំនាន់ឪពុកម្ដាយមានហេតុការណ៍កើតឡើងហើយមកជំនាន់នេះសប្បាយយ៉ាងម៉េចៗចឹងណាស់មីង ។

ឯមៈ ចាស ។

វណ្ណៈ ចឹងបទសម្ភាសខ្ញុំជាមួយមីងហ្នឹង តើមីងអនុញ្ញាតឲ្យខ្ញុំយកទៅសរសេរបានដឹងបានឮបានទេ ?

ឯមៈ បើនិយាយហើយសរសេរហ្នឹងហើយ ។

វណ្ណៈ បាទ!ចឹងមិនអីទេមីង?

ឯម: ចាស ។

វណ្ណៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអីដែរ?

ឯម: ឈ្មោះ កាន់ ឯម ។

វណ្ណៈ មីងអាយុប៉ុន្មានហើយ?

ឯម: អាយុ៥២ ។

វណ្ណៈ ចឹងប្តីមីងឈ្មោះអី?

ឯម: ឈ្មោះ ឈឹម អៀម ។

វណ្ណៈ គាត់អាយុប៉ុន្មានដែរ?

ឯម: អាយុ៥៨ ។

វណ្ណៈ ចឹង៥៨?

ឯម: ចាស ។

វណ្ណៈ កូនមីងមានប៉ុន្មាននាក់?

ឯម: ពីរនាក់ ។

វណ្ណៈ ស្រី?

ឯម: ស្រី១ប្រុស១ ។

វណ្ណៈ ឪពុកមីងឈ្មោះអីដែរ?

ឯម: ឈ្មោះ កាន់ ម៉េត ។

វណ្ណៈ ម្តាយ?

ឯម: រស់ ស៊ុម ។

វណ្ណៈ ចឹងគាត់នៅរស់ដែលឬស្លាប់អស់ហើយ?

ឯម: គាត់ស្លាប់អស់ហើយ ។

វណ្ណៈ ស្លាប់តាំងពីជំនាន់ណា?

ឯម: ស្លាប់តាំងពីឆ្នាំ៨៧-៨៥ម៉េ្ង ។

វណ្ណៈ ស្លាប់ក្រោយ៧៩?

ឯម: ចាស ។

វណ្ណៈ បងប្អូនមីងបង្កើតមានប៉ុន្មាននាក់?

ឯម: បងប្អូនមានបួននាក់ ។

វណ្ណៈ សព្វថ្ងៃនៅសល់ប៉ុន្មាន?

ឯមៈ បងប្អូន៥ តែស្លាប់មួយសល់៤ ។

វណ្ណៈ ចឹងមាន៥ នាក់?

ឯមៈ ចាស ។

វណ្ណៈ ចឹងសព្វថ្ងៃរស់នៅស្រុកកំណើតឬមួយមករស់នៅទីនេះដែរ?

ឯមៈ នៅស្រុកកំណើតមកតែខ្ញុំ ។

វណ្ណៈ ចឹងមានស្លាប់មួយដោយសារមូលហេតុអី?

ឯមៈ ស្លាប់ដោយសារឈឺគ្រុនចាញ់ ។

វណ្ណៈ ចឹងកាលហ្នឹងបងប្អូនមីងបានចូលបដិវត្តប៉ុន្មាននាក់ដែរ?

ឯមៈ កាលហ្នឹងចូលតែខ្ញុំពីរនាក់?

វណ្ណៈ ចូលពីរនាក់?

ឯមៈ ចាស ។

វណ្ណៈ ចឹងខ្ញុំចង់សួរទាក់ទងភូមិកំណើតសិន ភូមិកំណើតមីងនៅណា?

ឯមៈ ភូមិនៅភូមិចំហ៊ុក ។

វណ្ណៈ ឃុំ?

ឯមៈ ឃុំសម្បូរមាស ។

វណ្ណៈ សំបូរមាសឬសម្បូរមាស?

ឯមៈ មិនដឹងសំបូរឬសម្បូរខ្ញុំមិនបានចាំដែរ ។

វណ្ណៈ ចឹងស្រុកអីគេ?

ឯមៈ ស្រុកកំពង់សៀម ។

វណ្ណៈ ខេត្ត?

ឯមៈ ខេត្តកំពង់ចាម ។

វណ្ណៈ ឥឡូវមីងនៅភូមិអី?

ឯមៈ នៅភូមិពេជ្រចិន្តា ។

វណ្ណៈ ឃុំ?

ឯមៈ ឃុំពេជ្រចិន្តា ។

វណ្ណៈ ស្រុក?

ឯម៖ ស្រុកភ្នំព្រឹក ។

វណ្ណៈ ខេត្ត?

ឯម៖ ខេត្តបាត់ដំបង ។

វណ្ណៈ កាលនៅតូចមីងរៀនដល់ថ្នាក់ណា?

ឯម៖ ខ្ញុំរៀនបានថ្នាក់ទី១០ ។

វណ្ណៈ ចឹងទី១០ "ចាស់"?

ឯម៖ ចាស ។

វណ្ណៈ ចឹងនៅពេលឈប់រៀននៅឆ្នាំណា?

ឯម៖ ឈប់រៀននៅឆ្នាំ៧០ ។

វណ្ណៈ ចឹងឈប់រៀននៅពេលដែលកើតមានរដ្ឋប្រហា?

ឯម៖ ចាស! កើតរដ្ឋប្រហាហើយខ្ញុំឈប់ ។

វណ្ណៈ ពេលឈប់រៀនកើតរដ្ឋប្រហាហ្នឹងមីងមកធ្វើអីវិញ?

ឯម៖ មកមើលក្មួយជាមួយម៉ែ ។

វណ្ណៈ ចឹងនៅជាមួយឪពុកម្តាយ?

ឯម៖ ចាស ។

វណ្ណៈ ចឹងនៅឆ្នាំណាដែលមីងចូលបដិវត្ត?

ឯម៖ នៅឆ្នាំ៧៣ អ៊ះ! ៧៥ បានខ្ញុំចូល តែកាលឆ្នាំ៧៣ខ្ញុំជម្លៀសមកនៅស៊ឹងត្រង់ ។

វណ្ណៈ ជម្លៀសមកទាំងគ្រួសារ?

ឯម៖ អត់ផង ។

វណ្ណៈ ចឹងជម្លៀសតែមីងទេ?

ឯម៖ ជម្លៀសក្រុមគ្រួសារខ្ញុំមកហ្នឹង ។

វណ្ណៈ កាលហ្នឹងនៅស្ទឹងត្រង់?

ឯម៖ ចាស ។

វណ្ណៈ ចឹងនៅពេលខ្មែរក្រហមឈ្នះនៅឆ្នាំ១៩៧៥ មីងបានត្រឡប់ទៅភូមិវិញ?

ឯម៖ អត់ទៅផងខ្ញុំចូលនៅក្នុងភូមិ ។

វណ្ណៈ នៅស្ទឹងត្រង់ហ្នឹងតែម្តង?

ឯម៖ ចាស! នៅភូមិ៣៥ ហ្នឹង ។

វណ្ណៈ ចឹងឆ្នាំ១៩៧៥ ចូលបដិវត្តនៅស៊ីនត្រង់ហ្នឹង?

ឯមៈ ចាស ។

វណ្ណៈ ចឹងឈ្មោះភូមិ៣៥?

ឯមៈ ចាស ។

វណ្ណៈ នៅហ្នឹងក្នុងឃុំអី?

ឯមៈ មិនស្គាល់ដែរ ។

វណ្ណៈ ចឹងអត់ចាំទេ?

ឯមៈ ចាស! អត់ចាំ ។

វណ្ណៈ កាលមីងចូលកាលហ្នឹងគេបង្ខំឲ្យចូលឬមួយចូលដោយស្មគ្រ័ចិត្តទេកាលហ្នឹង?

ឯមៈ កាលហ្នឹងចូលដោយស្មគ្រ័ចិត្ត ។

វណ្ណៈ ចឹងកាលហ្នឹងស្មគ្រ័ចិត្តទេ?

ឯមៈ ចាស ។

វណ្ណៈ មីងយល់ឃើញយ៉ាងម៉េច?

ឯមៈ យល់ឃើញថាគេចូលសប្បាយចេះតែចូលហ្នឹងគេទៅ ។

វណ្ណៈ ចឹងអត់មានបានស្តាប់តាមការអំពាវនាវឬតាមការឃោសនាយ៉ាងម៉េចទេ?

ឯមៈ អត់ផង ។

វណ្ណៈ ចឹងកាលមីងចូលដំបូងមីងចូលទៅធ្វើអីដែរ?

ឯមៈ នៅក្នុងមន្ទីរចាក់ជ័រជូនរដ្ឋចឹងទៅណាស់ ។

វណ្ណៈ ចឹងនៅមន្ទីរចំការកៅស៊ូចឹង?

ឯមៈ ចាស ។

វណ្ណៈ ចឹងចាក់ជ័រជូនរដ្ឋ?

ឯមៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងជៀកៅស៊ូហ្នឹងទាំងស្រីទាំងប្រុសឬមួយយ៉ាងម៉េច?

ឯមៈ ចាស! ទាំងស្រីទាំងប្រុស ។

វណ្ណៈ មានច្រើនគ្នាទេមីង?

ឯមៈ ចាស ។

វណ្ណៈ ប្រហែលជាប៉ុន្មាននាក់ដែរ?

ឯមៈ	មួយភូមិមិនដឹងជាប៉ុន្មានទេ ខ្ញុំមិនសួរដែលដឹងដែរ ។

វណ្ណៈ	កន្លែងធ្វើការកន្លែងចំការកៅស៊ូហ្នឹង?

ឯមៈ	កន្លែងមន្ទីរនារីហ្នឹង ។

វណ្ណៈ	បាទ ។

ឯមៈ	មន្ទីរនារីយើងស្មានប្រហែលជា២០០នាក់ ។

វណ្ណៈ	បាទ ។

ឯមៈ	ខ្ញុំកាលហ្នឹងនៅតូចដែរ ។

វណ្ណៈ	ចឹងប្រហែលជា២០០នាក់មីង?

ឯមៈ	ចាស ។

វណ្ណៈ	ចឹងមីងធ្វើចាក់ជ័រកៅស៊ូរហូតដល់ពេលណាបានគេបញ្ជូនមកភ្នំពេញវិញ?

ឯមៈ	៧៥ខ្ញុំចូលហើយចាក់បានតែបន្តិចខ្ញុំឡើងមកភ្នំពេញ ។

វណ្ណៈ	ចឹង?

ឯមៈ	ចាស ។

វណ្ណៈ	ចឹងនៅឆ្នាំ៧៥ដដែលមីងមកភ្នំពេញហើយ?

ឯមៈ	ចាស!គេរំដោះហើយខ្ញុំមក ។

វណ្ណៈ	ចឹងកាលមកនៅភ្នំពេញហ្នឹងមីងមកនៅកន្លែងណា?

ឯមៈ	នៅដុំទួលគោក នៅមន្ទីរទួលគោក ។

វណ្ណៈ	នៅទួលគោកហ្នឹងមីងធ្វើអីកាលហ្នឹង?

ឯមៈ	កាលហ្នឹងអត់មានធ្វើអីផង ខ្ញុំមកជាមួយបងខ្ញុំជីដូនមួយមកនៅហ្នឹងជាមួយគាត់តែម្តងហើយ នារីនៅហ្នឹងក៏អត់មានធ្វើអីដែរ ។ គេថាយាមឃ្លាំងយាមអីចឹងទៅ ។

វណ្ណៈ	ជីដូនមួយប្រុសឬស្រី?

ឯមៈ	ប្រុស ។

វណ្ណៈ	ចឹងក្រោយមកជីដូនមួយប្រុសនិងគាត់ទៅណាទៀតទៅ?

ឯមៈ	គាត់បែកគាត់មកនៅផ្សេងខ្ញុំមកនៅនេះផ្សេងទៀត ឆ្នាំ៧៥ដែលចុង៧៥ខ្ញុំចេញមកបែកគ្នាហើយអាហ្នឹង ។

វណ្ណៈ	ចឹងបងមីងមួយទៀតចូលនៅខាងណាដែរ?

ឯមៈ	បងខ្ញុំនៅភូមិហ្នឹងវិញអត់មានមកទេ បងប្រុសខ្ញុំហ្នឹង ។

វណ្ណៈ	ចឹងនៅក្នុងភូមិគាត់ជាយោធា?

ឯមៈ	ចាស!គាត់កាន់ខាងសេដ្ឋកិច្ចបងខ្ញុំ ។

វណ្ណៈ	ចឹងសព្វថ្ងៃគាត់នៅរស់ដែរ?

ឯមៈ	គាត់នៅ ។

វណ្ណៈ	ចឹងមីងបែកពីបងប្រុសជីដូនមួយមកមីងទៅធ្វើខាងណាវិញ?

ឯមៈ	ខ្ញុំមកនៅស្តាតចាស់ ។

វណ្ណៈ	មកនៅស្តាតចាស់ធ្វើអីវិញ?

ឯមៈ	ស្តាតចាស់ហ្នឹងនៅបន្ទុបផ្ដើនផលខ្ញុំនៅច្រើនកន្លែងណាស់ ។

វណ្ណៈ	ចឹងធ្វើស្រែ?

ឯមៈ	អត់ធ្វើស្រែផង ។

វណ្ណៈ	ចឹងបន្ទុបផ្ដើនផល?

ឯមៈ	បផ្ដើនផលដាំស្ពៃបានមួយរយៈបានមកនៅឃ្លាំងរដ្ឋ មកនៅឃ្លាំងចឹងណាស់ ។

វណ្ណៈ	បាទ ។

ឯមៈ	គេហៅឃ្លាំងមុខព្រួញនៅមុខព្រួញនៅសម្ភារ ។

វណ្ណៈ	នៅឃ្លាំងរដ្ឋហ្នឹងគេមើលការខុសត្រូវស្អីខ្លះទៅ?

ឯមៈ	នៅឃ្លាំងមុខព្រួញហ្នឹងយើងដើររើសម្ភារតាមផ្ទះ ។

វណ្ណៈ	ចឹងដើររើសម្ភារតាមផ្ទះ?

ឯមៈ	ចាស!យើងរើយកមកដាក់មួយដុំៗមក ចានឆ្នាំងស្អីៗគេឲ្យរើចឹងទៅ រើតាមមុខព្រួញគេហ្នឹង ។

វណ្ណៈ	កាលហ្នឹងប្រធានពីណាគេ?

ឯមៈ	ខ្ញុំមិនស្គាល់ទេ ភ្លេចហើយ ខ្ញុំអត់ស្គាល់ទេប្រធានគេយូរហើយ ។

វណ្ណៈ	បាទ ។

ឯមៈ	ខ្ញុំភ្លេចឈ្មោះអស់ហើយ ។

វណ្ណៈ	ចឹងដល់ឆ្នាំ៧៦-៧៧អីមីងនៅឃ្លាំងរដ្ឋរហូតឬមួយយ៉ាងម៉េចដែរ?

ឯមៈ	ខ្ញុំនៅអូរឬស្សី ។

វណ្ណៈ	ចឹងនៅអូរឬស្សីធ្វើអីវិញ?

ឯមៈ	នៅដែរ ។

វណ្ណៈ នៅដេរវិញ?

ឯមៈ ចាស! ហ្នឹងនៅកាត់ដេររដ្ឋហើយហ្នឹង ។

វណ្ណៈ នៅឆ្នាំ៧៦-៧៧ហ្នឹង?

ឯមៈ ចាស ។

វណ្ណៈ ចឹងនៅកាត់ដេររហូតដល់៧៩?

ឯមៈ ខ្ញុំនៅហ្នឹងដល់៧៩រត់និងបណ្តោយ ។

វណ្ណៈ ចឹងកាលនៅកាត់ដេរប្រធានពីណាវិញ?

ឯមៈ ប្រធានភ្លេចឈ្មោះហើយពូអើយ ឥឡូវយើងមិនដែលបានរាប់រកគាត់ ។

វណ្ណៈ បាទ! ចឹងគ្នាច្រើនទេនៅកន្លែងកាត់ដេរហ្នឹង?

ឯមៈ មានគ្នាច្រើនរាប់ពាន់នាក់មិនមែនតិចទេទាំងស្រីទាំងប្រុសនោះ ។

វណ្ណៈ បាទ ។

ឯមៈ នៅផ្សារអូរឫស្សីហ្នឹងនោះ ផ្សារអូរឫស្សីចាស់ ។

វណ្ណៈ ចឹងមានមនុស្សរាប់ពាន់នាក់?

ឯមៈ ចាស ។

វណ្ណៈ កាលហ្នឹងកាត់ដេរខោអាវយ៉ាងម៉េចដែរ?

ឯមៈ ខោអាវខ្មៅ ។

វណ្ណៈ ខោអាវខ្មៅ?

ឯមៈ ចាស ។

វណ្ណៈ កាត់ដេរហ្នឹងមីងមានដឹងថាកាត់ដេរយកទៅខាងណាមីងមានដឹងទេ?

ឯមៈ យកចែកប្រជាជនយកចែកក្នុងជួរយើងហ្នឹង ។

វណ្ណៈ បាទ ។

ឯមៈ ក៏ចែកដែរ នៅតាមមន្ទីរ?

វណ្ណៈ បាទ! ចឹងកាលមីងនៅកាត់ដេរអត់មានស្គាល់អ៊ីរិទ្ធអីទេ?

ឯមៈ អត់ស្គាល់ទេ ។

វណ្ណៈ ចឹងប្រធានមន្ទីរអីហ្នឹងមីងភ្លេចអស់ហើយ?

ឯមៈ មិនស្គាល់ទេ ភ្លេចអស់ហើយ ។

វណ្ណៈ ចឹងកាលមីងនៅកាត់ដេរហ្នឹងមីងដែលឃើញពួកចិនទៅទស្សនកិច្ចទេ?

ឯមៈ ទស្សនកិច្ចដែរ ។

វណ្ណៈ ចឹង?

ឯមៈ ចាស ។

វណ្ណៈ មានបរទេសច្រើនទេ?

ឯមៈ មាន ។

វណ្ណៈ មានជនជាតិទៅកន្លែងកាត់ដេរហ្នឹងទេ?

ឯមៈ កន្លែងកាត់ដេរហ្នឹងអត់មានមកទេពូ ពួកខ្ញុំចេញទៅទទួលគេនៅក្រៅវិញ ។

វណ្ណៈ ចេញទទួលនៅក្រៅកន្លែងណាវិញ?

ឯមៈ នៅតាមមាត់ទន្លេផ្ទះលេខ១អីចឹងណាស់ មានផ្ទះគេបើថាឲ្យគេមកចូលហ្នឹងមិនដែលចូលទេ ។

វណ្ណៈ ចឹង?

ឯមៈ ចាស ។

វណ្ណៈ ចឹងកាលមីងនៅកាត់ដេរហ្នឹងមានឃើញអ្នកធំណាទៅមើលទេ អ្នកធំដូចជាប៉ុល ពត អៀង សារី?

ឯមៈ គាត់មិនដែលចូលផង ដល់ប្រជុំបានយើងទៅប្រជុំ ។

វណ្ណៈ ប្រជុំនៅណា?

ឯមៈ ប្រជុំនៅកន្លែងស្តាតអូឡាំពេជ្រ ។

វណ្ណៈ បាទ ។

ឯមៈ ហើយខាងក្រោយស្តាតហ្នឹងគេហៅ“ក-៦”ៗហ្នឹង ។

វណ្ណៈ បាទ ។

ឯមៈ មកប្រជុំនិងឯងមករៀនជាមួយគាត់អីហ្នឹង ។

វណ្ណៈ មករៀនជាមួយពីណាគេ?

ឯមៈ ជាមួយអ៊ឹ ។

វណ្ណៈ ជាមួយអ៊ឹណា?

ឯមៈ អ៊ឹខៀវ ។

វណ្ណៈ អ៊ឹខៀវ សំផន?

ឯមៈ ចាស ។

វណ្ណៈ រៀនសូត្រហ្នឹងគេប្រជុំពីអីខ្លះ?

ឯម៖ យើងបន្តបង្កើនផលរៀងស្រែរៀងចំការហ្នឹងគេណែនាំ ។

វណ្ណៈ ជាមួយលោកខៀវ សំផនហើយមានពីណាទៀត?

ឯម៖ អ៊ឹងអៀង សារីអ៊ឹងអីហ្នឹង ។

វណ្ណៈ ចឹងកាលមីងធ្វើការនៅភ្នំពេញកាលឆ្នាំ៧៥-៧៦-៧៧អីកម្មកររោងចក្រមានអាហារហូបគ្រប់គ្រាន់អត់មានអីទេ?

ឯម៖ អត់អីទេ ហូបគ្រប់គ្រាន់ ។

វណ្ណៈ តែមីងនៅខាងកំពង់ចាម កាលហ្នឹងគេចាប់សោភីមទៅ កាលហ្នឹងមីងនៅខាងបូព៌ាឬមីងនៅខាងបស្ចឹម កាលមីងចូលបដិវត្តហើយមីងមកនៅភ្នំពេញ?

ឯម៖ ចាស ។

វណ្ណៈ កាលហ្នឹងគេមានបែងចែកមានបូព៌ា ពាយ័ព្យ បស្ចឹមអីចឹង?

ឯម៖ កាលហ្នឹងគេបែកចែកដែលតែខ្ញុំកាលហ្នឹងអត់អីផង ។

វណ្ណៈ ចឹងមីងអត់អីទេ?

ឯម៖ ចាស ។

វណ្ណៈ បើផ្នែកកងទ័ពបានមានបញ្ហា?

ឯម៖ ចាស ។

វណ្ណៈ ចឹងកាលមីងនៅកន្លែងកាត់ដេរហ្នឹងមានគេចាប់ខ្លួនឬមានបាត់អីដែរឬក៏អត់ទេ?

ឯម៖ អត់ផងនៅពេញៗ ។

វណ្ណៈ ចឹងកាលមីងមកមុខវាំងអីកាលហ្នឹងទទួលពីណាគេ?

ឯម៖ ទទួលចិន ។

វណ្ណៈ ចិន?

ឯម៖ ចាស ។

វណ្ណៈ ចឹងក្រៅពីចិនមានឃើញប្រទេសអីទៀត?

ឯម៖ ទទួលចិន ទទួលកូរេទៅជួនកាលទទួលភូមា ។

វណ្ណៈ ចឹង?

ឯម៖ ចាស!ឲ្យតែមានភ្ញៀវមកយើងទៅទទួលហើយ ។

វណ្ណៈ យ៉ាងម៉េចបានមីងស្គាល់ចិនស្គាល់ភូមា?

ឯម៖ ចុះគេប្រាប់មុនយើងទៅគេប្រាប់ថាថ្ងៃនេះភ្ញៀវមកហើយទទួលភ្ញៀវអីភ្ញៀវចិន ។

វណ្ណៈ	បាទ ។

ឯមៈ	ហកភ្ញៀវកូរេ ភ្ញៀវកូមាចឹងណាស់ ។

វណ្ណៈ	ចឹងនៅពេលទទួលគេគ្រាន់តែឲ្យយើងទៅអមផ្លូវ?

ឯមៈ	ចាស!អមផ្លូវចឹងណាស់ ។

វណ្ណៈ	ចឹងមានបានរៀបចំណីអាហារទេ?

ឯមៈ	អត់ទេ យើងគ្រាន់អមផ្លូវចូលកន្លែងគេទៅហើយយើងមកវិញមក ។

វណ្ណៈ	ចឹងមីងបាននៅក្នុងភ្នំពេញរយៈពេលបីឆ្នាំជាងហ្នឹង មីងមានដឹងថាសម្ដេចសីហនុនៅក្នុងវាំងដែលទេ?

ឯមៈ	អត់ដឹងផង ។

វណ្ណៈ	ចឹងអត់បានដឹងទេ?

ឯមៈ	ចាស!អត់ដឹងទេ ។

វណ្ណៈ	ចឹងមកដល់ឥឡូវមីងមានបានដឹងទេ?

ឯមៈ	ឥឡូវក៏អត់ដឹង មិនគាត់ទៅនៅណា ។

វណ្ណៈ	ចឹងជំនាន់ប៉ុល ពតមីងមិនបានដឹងថាគាត់នៅក្នុងវាំងដែរ?

ឯមៈ	អត់ដឹងផង ។

វណ្ណៈ	សម្ដេចនៅក្នុងវាំងតើ ។

ឯមៈ	ចាស ។

វណ្ណៈ	កាលហ្នឹងគា ខៀវ សំផនជាអ្នកមើលការខុសត្រូវបាយទឹកឲ្យគាត់ ។

ឯមៈ	ចាស ។

វណ្ណៈ	ចឹងកាលមីងនៅកាត់ដេរហ្នឹងមិនមានជួបការលំបាកអីទេ?

ឯមៈ	អត់ទេ ។

វណ្ណៈ	ចឹងមីងមានបានសុំមកលេងផ្ទះសំបែងទេ?

ឯមៈ	៧៩ គេបើកឲ្យមកលេង ។

វណ្ណៈ	៧៩ បែកហ្នឹង?

ឯមៈ	៧៩ តែមុនរត់ហ្នឹង ។

វណ្ណៈ	មុនរត់វប៉ុន្មានថ្ងៃទៅ?

ឯមៈ	មុនរត់ប្រហែលជាមួយខែដឹង ។

វណ្ណៈ បាទ ។

ឯមៈ ព្រោះខ្ញុំទៅលេងផ្ទះមកវិញសភាពការណ៍អត់ស្រួលរហូត ។

វណ្ណៈ ចឹងទៅលេងបានជួបបងប្អូនទេ?

ឯមៈ ចាស!ជួបម៉ែនៅស៊ីងត្រង់ហ្នឹង ។

វណ្ណៈ ចឹងមីងទៅដល់សហករណ៍ឃើញសហករណ៍គេហូបចុកយ៉ាងម៉េចដែរ?

ឯមៈ ហូបចុកអត់អីដែលឃើញគាត់នេះដែរ ។

វណ្ណៈ ចឹងមានកន្លែងចខ្វះមិនអីទេ?

ឯមៈ ចាស!យើងម៉េចដឹងបើយើងទៅបានពីរបីថ្ងៃហ្នឹងមកវិញ ។

វណ្ណៈ ចឹងមីងបានទៅពីរបីថ្ងៃដែរ?

ឯមៈ ចាស ។

វណ្ណៈ ចឹងគេអនុញ្ញាតឲ្យទៅដែរ?

ឯមៈ ចាស!គេជូនដល់ផ្ទះឡាន ។

វណ្ណៈ ចឹងនៅពេលមីងបានត្រឡប់មកភ្នំពេញវិញមីងមានបាននិយាយប្រាប់មិត្តភក្តិថានៅស្រុកចំការយ៉ាងម៉េចដែលអត់?

ឯមៈ ខ្ញុំថាបានជួបម៉ែឪសុខសប្បាយចឹងទៅ គាត់អត់មានអីទេចឹងទៅ ព្រោះគាត់អត់មានប្រាប់យើងថាអីផង ។

វណ្ណៈ ចឹងកាលហ្នឹងមីងមានបានដឹងថាប្រជាជនមួយចំនួនស្លាប់ដោយសារអត់បាយឬគេសម្លាប់អីមីងមានបានដឹងទេ កាលមីងនៅធ្វើការភ្នំពេញ?

ឯមៈ អត់ដឹងទេ ខ្ញុំនៅភ្នំពេញមិនដែលដឹងទេ ។

វណ្ណៈ ព្រោះអីកម្មករឬយោធានៅភ្នំពេញអីមានការហូបចុកគ្រប់គ្រាន់ ។

ឯមៈ ចាស ។

វណ្ណៈ ខ្លះមិនបានទៅលេងផ្ទះចឹងក៏អត់ដឹងថាមានការសម្លាប់មនុស្សដែរ?

ឯមៈ ចាស ។

វណ្ណៈ ចឹងនៅពេលបែកភ្នំពេញនៅឆ្នាំ៧៩ហ្នឹងហេតុអីបានជាមីងមិនរត់ទៅស្រុកកំណើត?

ឯមៈ ចុះកាលហ្នឹងថាឲ្យជម្លៀសមួយរយៈសិន ។

វណ្ណៈ និយាយ៧៩វៀតណាមចូលមកហ្នឹង?

ឯមៈ ចាសឲ្យជម្លៀសមួយរយៈសិនយួនចូលថាចឹងទៅណាស់ ។

វណ្ណៈ បាទ ។

ឯម: ដល់ចឹងពួកខ្ញុំធម្មតានៅក្រោមការគ្រប់គ្រងរបស់គេ ឲ្យជម្លៀសយើងមិនមកតាម ។

វណ្ណៈ ចឹងមីងដើរឬមួយជិះឡានកាលហ្នឹង?

ឯម: ដើរ ។

វណ្ណៈ ដើរកាត់តាមណា កាលចេញពីភ្នំពេញ?

ឯម: ចេញពីភ្នំពេញមកដើរកាត់តាមនេះ ចេញផ្លូវពោធិចិនតុង ។

វណ្ណៈ បាទ! ហើយតាមណាទៀត?

ឯម: មកលិចរហូតមកមិនស្គាល់មិនដឹងជាភូមិស្អីភូមិស្អីទេ ខ្ញុំមិនបានស្គាល់ដែរ ។

វណ្ណៈ ដើររហូត?

ឯម: ដើររហូត ។

វណ្ណៈ ចឹងកាលហ្នឹងមានការពិតទេ ថាដើរមកដល់ភ្នំអីចឹងមានអ្នកស្លាប់ដោយសារអត់មានអាហារ ដោយសាគ្រួនចាញ់ស្លាប់តាមផ្លូវចឹងមីងមានបានជួបទេ?

ឯម: មានៗ ។

វណ្ណៈ ចឹងមានដែរ?

ឯម: ចាស! ដូចថាឈឺចឹងគេដាក់ចោលយើងមកតាមក្រោយឃើញស្លាប់ ហើយយើងចេះតែទៅៗអ្នកស្លាប់នៅស្លាប់ហ្នឹងទៅ ។

វណ្ណៈ បាទ ។

ឯម: ចឹងមានមែន ។

វណ្ណៈ ចឹងមីងខ្លាចទេកាលហ្នឹង?

ឯម: ខ្ញុំអត់មានខ្លាចទេកាលហ្នឹងខ្ញុំចូលទ័ពដែរ ដល់មកខ្ញុំនារីមិនចូលទ័ព ។

វណ្ណៈ បាទ ។

ឯម: ខ្ញុំមកតាមទ័ពមករហូត ។

វណ្ណៈ ចឹងកាលមីងមកដល់ព្រំដែនហ្នឹងនៅឆ្នាំ៧៩ដែរ?

ឯម: ចាស ។

វណ្ណៈ ៧៩ហ្នឹងមីងមកដល់ណាមុនគេ នៅច្រកណានៅខាងណាព្រំដែន?

ឯម: មកតាមច្រកកំរៀងឈប់នៅកំរៀងហ្នឹងឯង ។

វណ្ណៈ កំរៀង?

ឯម៖ ចាស ។

វណ្ណៈ ហើយទៅខាងណាទៀត?

ឯម៖ មកនៅកំរៀងមកនៅហ្នឹងរហូតតាមហែរៗហ្នឹងអត់មានទៅណាទៀតទេ ។

វណ្ណៈ ចឹងមីងមានបានទៅជិះអីទេ?

ឯម៖ អត់ទេ ខ្ញុំអត់មានទៅនៅតាមព្រំដែននិងរហូត ។

វណ្ណៈ ចឹងអត់មានបំណងរត់ទៅក្រៅប្រទេសអីទេ?

ឯម៖ អត់ផង កាលហ្នឹងខ្វះអីគេអ្នកទៅ ខ្ញុំអត់មានចុះឈ្មោះទៅនិងគេផង ។

វណ្ណៈ មីងគិតយ៉ាងម៉េចបានជាមីងមិនចង់ទៅ?

ឯម៖ មានគិតយ៉ាងម៉េច គេថាយកតែអ្នកឈឺហើយខ្ញុំអត់ឈឺ ។

វណ្ណៈ បាទ ។

ឯម៖ អ្នកឈឺៗគេបានទៅ អ្នកឈឺគេយកទៅពេទ្យហើយមិនដឹងជាគេយកទៅណា ខ្ញុំមិនបានដឹងដែលយើងអត់ឈឺនៅទៅ ។

វណ្ណៈ ចឹងកាលមីងមកដល់ដំបូងតាមកំរៀងអីហ្នឹង មីងឃើញមានវាលចឹងឬមួយសុទ្ធតែព្រៃ?

ឯម៖ សុទ្ធតែព្រៃ ។

វណ្ណៈ ចឹងកន្លែងនេះអីសុទ្ធតែព្រៃ?

ឯម៖ កន្លែងហ្នឹងព្រៃណែនហើយពួកខ្ញុំមកកាប់ ខ្ញុំឡើងមកនៅនេះខ្ញុំកាប់ នៅកំរៀងនៅនាវីមកដល់មានតែភូមិកំរៀងទេវាលនោះ ។

វណ្ណៈ បាទ ។

ឯម៖ កន្លែងភូមិចាស់គេហ្នឹង ។

វណ្ណៈ ចឹងមានភូមិចាស់មួយដែរ?

ឯម៖ ចាស ។

វណ្ណៈ ចឹងមានភូមិចាស់ពីដើមមកតែម្តង?

ឯម៖ ចាស!ពីដើម ។

វណ្ណៈ តែភូមិតូចមួយទេ?

ឯម៖ ភូមិតូច តែគ្រាន់ដឹងថាភូមិតែមិនមានឃើញផ្ទះឃើញអីទេ វាឆេះខ្ទិចខ្ទីអស់ទៅដឹងរុះរើទៅណាផង គ្រាន់ដឹងថាភូមិចាស់និងឯង ។

វណ្ណៈ ចឹងក្រៅពីហ្នឹងសុទ្ធតែព្រៃសុទ្ធ?

ឯមៈ ចាស!សុទ្ធតែព្រៃ។

វណ្ណៈ ចឹងកាលមីងមកដល់ព្រំដែននិងមីងនៅក្រុមដឹកជញ្ជូនឬមួយមីងឡើងវិញដែរ?

ឯមៈ ខ្ញុំនៅក្រុមដឹកជញ្ជូន។

វណ្ណៈ ចឹងនៅក្រុមដឹកជញ្ជូន?

ឯមៈ ចាស។

វណ្ណៈ ចឹងខាងបុរសៗឡើងវិញ?

ឯមៈ ចាស។

វណ្ណៈ ចឹងកាលវិញតាំងពីឆ្នាំ៧៩ដល់ឆ្នាំ៨១-៨២អីហ្នឹងទាំងខ្មែរក្រហមទាំងទាហានយួនមានស្លាប់ច្រើនទេ ខាងយើងក៏ស្លាប់ខាងយួនក៏ស្លាប់ឬមួយយ៉ាងម៉េចដែរ ស្លាប់របួសអីយ៉ាងម៉េចដែរមីង?

ឯមៈ កាលហ្នឹងដូចជាមិនសូវមានរបួសប៉ុន្មានទេខ្មែរយើង។

វណ្ណៈ ចឹងខាងយួន?

ឯមៈ ខាងយួនមិនដឹងយ៉ាងម៉េច។

វណ្ណៈ ចឹងមីងជាអ្នកជញ្ជូនគ្រាប់មីងមិនសូវដឹងទេ?

ឯមៈ ចាស។

វណ្ណៈ ហើយរបបហូបចុកអីមានគ្រប់គ្រាន់?

ឯមៈ ចាស។

វណ្ណៈ ចឹងសម្ភារអាវុធអីបានមកពីខាងណា?

ឯមៈ មកពីថៃ។

វណ្ណៈ មកពីថៃ?

ឯមៈ ចាស។

វណ្ណៈ មានដឹងថាប្រទេសណាជួយទេ?

ឯមៈ អត់បានដឹងផង។

វណ្ណៈ ចឹងដឹងថាមកពីថៃ?

ឯមៈ ចាស។

វណ្ណៈ ចឹងកាលហ្នឹងយើងមានការទំនាក់ថៃអីល្អអត់មានដែលឈ្លួសគ្នាទេ?

ឯមៈ អត់ផង។

វណ្ណៈ ចឹងនៅពេលដែលវៀតណាមវ៉ៃខ្លាំងអីរត់ទៅដីថៃឬមួយយ៉ាងម៉េច?

ឯមៈ រត់ទៅដីថៃ ។

វណ្ណៈ ចឹងរត់ទៅដីថៃ?

ឯមៈ ចាស ។

វណ្ណៈ កាលហ្នឹងវ៉ៃខ្លាំងទេកាលហ្នឹង?

ឯមៈ វ៉ៃខ្លាំង កាលហ្នឹងពួកខ្ញុំរត់ទៅប៉ៃលិនម្ដង រត់ទៅប៉ៃលិនដល់យើងវ៉ៃឈ្នះយើងរត់មកវិញ ។

វណ្ណៈ ចឹងមីងអត់មានបានរត់ទៅខាងម៉ាឡៃទៅស្វាយចេកទៅថ្មពួកអីទេ?

ឯមៈ អត់ទេ ។

វណ្ណៈ ចឹងមីងនៅខាងកំរៀងភ្នំព្រឹកនេះ?

ឯមៈ ចាស ។

វណ្ណៈ ចឹងនៅជំនាន់ខាងហ្នឹងក្រោយ៧៩ហ្នឹងពីណាជាប្រធានកងពល?

ឯមៈ ដឹងពីណាទេ ។

វណ្ណៈ តា កន?

ឯមៈ មានតែតា កននិងឯង ។

វណ្ណៈ ហើយចុះសុន សេន?

ឯមៈ តា ដល់ពេលគេផ្ដាច់និងហើយដល់ពេលគេផ្ដាច់គាត់បានគាត់បែកទៅបាត់ ។

វណ្ណៈ បាទ ។

ឯមៈ កាលហ្នឹងនៅគាត់ ។

វណ្ណៈ ចឹងមីងមានដឹងថានៅក្នុងព្រៃហ្នឹងក្រោយ៧៩ហ្នឹង ជំនាន់តា កននិងសុន សេនកាន់កាប់ហ្នឹង មីងមានដឹងថាក្នុងព្រៃហ្នឹងមានគុកទេ គុកសម្រាប់អប់រំអី?

ឯមៈ អត់មានផង ។

វណ្ណៈ អត់មានទេ?

ឯមៈ ចាស ។

វណ្ណៈ ចឹងគេថា មានគុកតា ចាន់?

ឯមៈ គុកតា ចាន់នៅអីនោះ ។

វណ្ណៈ នៅណា?

ឯមៈ នៅជើងនោះ ។

វណ្ណៈ នៅកន្លែងអីគេ គេហៅភូមិអីភូមិហ្នឹង?

ឯមៈ គុកគា ចាន់នៅភ្នំដីនោះ ។

វណ្ណៈ នៅភ្នំដី?

ឯមៈ ចាស ។

វណ្ណៈ ភ្នំដីកន្លែងហ្នឹងគេហៅ២៥០ដែរ?

ឯមៈ ចាស ។

វណ្ណៈ ចឹងមីងមានដឹងថាគុកហ្នឹងគេដាក់អ្នកទោសយ៉ាងម៉េចអីទេ?

ឯមៈ អត់ដឹងផង ។

វណ្ណៈ ភ្នំដីមន្ទីរ២៥០ចឹងមីង?

ឯមៈ ចាស!ខ្ញុំមិនសូវដែលដឹងដែរ ។

វណ្ណៈ ចឹងកាលពីមុននិងជាព្រៃវីព្រៃខ្វាតែម្តង?

ឯមៈ ចាស ។

វណ្ណៈ មើលពន្លឺថ្ងៃអីឃើញទេ?

ឯមៈ អត់មានទេ ព្រៃសុទ្ធតែម្តងក្រាស់ខ្មឹប ។

វណ្ណៈ មើលថ្ងៃឃើញទេ?

ឯមៈ ចូលទៅមើលថ្ងៃមិនឃើញទេ សុទ្ធតែព្រៃសុទ្ធជិតឈើងតែម្តង ។

វណ្ណៈ ចឹងមានជំងឺគ្រុនចាញ់ច្រើនទេ?

ឯមៈ ចាញ់ ។

វណ្ណៈ ចឹងមានចាញ់ស្លាប់ច្រើនដែរ?

ឯមៈ ចាស!៧៩ឆ្នាំ៨០អីហ្នឹងចាញ់ផ្តុំអូរអន្ទក់នេះស្លាប់ប្រជាជន គាត់មានកូនចៅចឹងទៅស្លាប់ពួក
នារីហ្នឹងក៏មានស្លាប់ដែរ ខ្ញុំអីសុទ្ធតែអ្នកសល់ពីស្លាប់ហើយ អ្នកសល់ពីចាញ់ហើយនៅនេះ ។

វណ្ណៈ ចឹងសុទ្ធតែចាញ់ឆ្អែតហើយ?

ឯមៈ ចាស ។

វណ្ណៈ ខ្លះថាចាញ់ជ្រុះសក់អីនោះ?

ឯមៈ ខ្លះចាញ់ជ្រុះសក់ ញញ័រញញ័រខ្លះអ្នកអត់ចាញ់ៗ គ្រួសារខ្ញុំនេះទៅប៉ៃលិនចាញ់អ៊ូមិនបាន
ទេ ញាក់មួយថ្ងៃៗហើយខ្ញុំអត់អី ។

វណ្ណៈ ចឹងកាលមីងបានពូបានយ៉ាងម៉េចដែរ?

ឯមៈ	រៀបធម្មតា ។

វណ្ណៈ	រៀបនៅជំរំ?

ឯមៈ	អត់ទេ រៀបយើងនៅអូរអន្ទក់ ។

វណ្ណៈ	មីងរៀបមានប៉ុន្មានគូរ?

ឯមៈ	រៀបបីគូរ ។

វណ្ណៈ	បីគូរ?

ឯមៈ	ចាស ។

វណ្ណៈ	មានលោកសង្ឃអីទេ?

ឯមៈ	អត់ផង ។

វណ្ណៈ	មានអាចារ្យដែរ?

ឯមៈ	អត់ផង ។

វណ្ណៈ	ការឆ្នាំណា?

ឯមៈ	ការឆ្នាំ៨១ ។

វណ្ណៈ	តែកាលហ្នឹងយើងមានសិទ្ធរើស?

ឯមៈ	ចាស ។

វណ្ណៈ	យើងអាចត្រូវចិត្តគ្នា?

ឯមៈ	ចាស!អត់មានគេបង្ខំទេ ។

វណ្ណៈ	ចឹងនៅពេលពូរៀបការជាមួយមីងហើយគាត់នៅទៅសមរភូមិមុខដដែលឬមួយឈប់?

ឯមៈ	ហ្នឹងហើយគាត់ទៅមុខ ។

វណ្ណៈ	ចឹងទៅប្រយុទ្ធនៅមុខដដែល?

ឯមៈ	ចាស ។

វណ្ណៈ	ចឹងមីងឈប់ហើយ?

ឯមៈ	ខ្ញុំឈប់ហើយឈប់ដឹកជញ្ជូនហើយហ្នឹង ។

វណ្ណៈ	ចឹងនៅពេលដែលមីងរៀបការមីងមាននឹកឃើញឪពុកម្ដាយឬមួយយ៉ាងម៉េចដែរ អត់មានឪពុកម្ដាយចូលរួមចឹងយ៉ាងម៉េចដែរ?

ឯមៈ	នឹកឃើញដែលតែមិនដឹងជាធ្វើយ៉ាងម៉េច បើគាត់នៅឆ្ងាយ ។

វណ្ណៈ ហើយកាលហ្នឹងយើងមិនអាចទាក់ទងចេញចូលទៅបានទេ?

ឯមៈ ចាស!ចឹងកាត់ចិត្តទៅយើងយ៉ាងម៉េចគេម៉េចបែកយូរហើយដូចថានេះទៅ ។

វណ្ណៈ ចឹងយ៉ាងម៉េចបានជាមីងសម្រេចចិត្តយកគ្រួសារ?

ឯមៈ នឹកឃើញថាវាអាយុច្រើនហើយខ្ជិលនៅយកគ្រួសារហើយនឹកឃើញចឹង ។

វណ្ណៈ ចឹងនៅពេលដល់ឆ្នាំណាបានមីងទៅលេងផ្ទះបាន?

ឯមៈ ឥឡូវនេះ ។

វណ្ណៈ កាលពីជំនាន់គស៊ូហ្នឹងមីងមានបានទៅលេងផ្ទះអីទេ?

ឯមៈ អត់ទេ ទើបយើងផ្ដាច់ខ្លួនខ្ញុំទៅឆ្នាំមើល៩០ប៉ុន្មាននេះ ។

វណ្ណៈ ចឹងមីងមានដឹងថាផ្ដាច់ខ្លួននៅឆ្នាំណាដែរ?

ឯមៈ ផ្ដាច់ខ្លួនឆ្នាំ៩៧ ។

វណ្ណៈ ចឹង៩៦-៩៧?

ឯមៈ ចាស ។

វណ្ណៈ ចឹងនៅពេលដែលផ្ដាច់ខ្លួនហើយបានមីងទៅលេងផ្ទះបាន?

ឯមៈ ចាស ។

វណ្ណៈ ចឹងនៅពេលដែលបានទៅលេងផ្ទះហ្នឹងអ្នកស្រុកអ្នកភូមិឬឪពុកម្ដាយភ្ញាក់ផ្អើលយ៉ាងម៉េចដែរកាលហ្នឹង?

ឯមៈ គាត់មករក ។

វណ្ណៈ គាត់មករកដល់ហ្នឹងដែរ?

ឯមៈ ចាស!គាត់មករកមុនបានខ្ញុំទៅ ។

វណ្ណៈ មករកជួបទេ?

ឯមៈ ជួប ។

វណ្ណៈ គាត់មករកនៅឆ្នាំណា?

ឯមៈ គាត់មករកមើលឆ្នាំ.....?

វណ្ណៈ មុនផ្ដាច់ខ្លួនឬផ្ដាច់ខ្លួនហើយ?

ឯមៈ មុនផ្ដាច់ខ្លួន ។

វណ្ណៈ ចឹងយ៉ាងម៉េចបានចូលមកបានកាលហ្នឹងនៅខ្មែរក្រហម?

ឯមៈ គាត់មកតាមរយៈគេនោះគេនាំមក មកតាមរយៈគេនាំមក ។

វណ្ណៈ	ចឹងកាលហ្នឹងមានមេខ្យល់?

ឯមៈ	ចាស ។

វណ្ណៈ	មកបានជួបទេ?

ឯមៈ	មកជួបអត់អីដែរ គេអត់មានធ្វើអីយើងទេ ខាងនោះក៏អត់ធ្វើអីខាងនេះក៏អត់ធ្វើអីជិនាន់ហ្នឹងដូចថាស្គាល់ចឹងទៅ មោៗ ។

វណ្ណៈ	ចឹងកាលដែលគាត់មកជួបមីងហ្នឹង មីងមានផ្ទះមានអីនៅ?

ឯមៈ	ខ្ញុំមានផ្ទះហើយតែផ្ទះខ្ញុំនៅនោះ ។

វណ្ណៈ	នៅណាវិញ?

ឯមៈ	នៅភ្លើងឆេះនោះ ។

វណ្ណៈ	ភ្លើងឆេះនៅខាងណាវិញ?

ឯមៈ	នេះទៅពីភូមិនេះទៅ គេភូមិភ្លើងឆេះ ។

វណ្ណៈ	នៅក្នុងភ្នំព្រឹកហ្នឹង?

ឯមៈ	ចាស! នៅហ្នឹងដែរ ។

វណ្ណៈ	ចឹងកាលសម័យតស៊ូហ្នឹងគាត់មកបានប៉ុន្មានថ្ងៃគាត់ទៅវិញ?

ឯមៈ	មកបាន៥ថ្ងៃគាត់ទៅវិញ ។

វណ្ណៈ	គាត់មានបបួលមីងទៅស្រុកកំណើតវិញទេ?

ឯមៈ	អត់ផង គាត់អត់បបួលផងគាត់ទៅតាមផ្លូវនេះជូនទៅដល់ភូមិដូងទៅម៉ាឡៃហ្នឹងទៅ ជូនគាត់ដល់ត្រឹមហ្នឹង ។

វណ្ណៈ	ចឹង?

ឯមៈ	ជូនគាត់ដល់ត្រឹមហ្នឹងទៅ គាត់ជួបជុំគ្នាគាត់ គាត់ទៅវិញទៅ ។

វណ្ណៈ	បាទ ។

ឯមៈ	ដូចថាគាត់មកជាកងជាក្រុមរបស់គាត់ហ្នឹង ។

វណ្ណៈ	កាលហ្នឹងនៅខ្មែរក្រហមនៅឡើយទេ?

ឯមៈ	ចាស! នៅខ្មែរក្រហម ។

វណ្ណៈ	ចឹងមីងរស់នៅកាលហ្នឹងមានដឹងថា តា សុន សេនចង់ប្រមូលទ្រព្យសម្បត្តិដាក់រួមមួយសាទៀតអីមានទេកាលហ្នឹង?

ឯមៈ	អត់ដឹងផង ។

វណ្ណៈ ចឹងមីងមិនបានដឹងទេ?

ឯម: មិនបានដឹងទេ កាលហ្នឹង តែដូចមិនមានព្រុថាទេ នៅជិតនេះដូចថាមិនមានព្រុថាប្រមូលអីទេកាលហ្នឹង ។

វណ្ណៈ ចឹងមានដោយកន្ទែងទេ នៅកំរៀងអីមានប្រមូលខ្លះ?

ឯម: ចាស ។

វណ្ណៈ ចឹងដោយកន្ទែង?

ឯម: ដោយកន្ទែង ។

វណ្ណៈ ដូចថាភូមិឃុំកើតមានសព្វថ្ងៃនេះ មីងគិតថាកើតក្រោយសមាហរណ៍កម្មឬពីមុនមកមានឈ្មោះភូមិ ឃុំ ស្រុកអីហើយឬអត់មានទេ?

ឯម: អត់មានផងយើងដាក់ ។

វណ្ណៈ ចឹងយើងដាក់ក្រោយនេះទេ?

ឯម: ចាស!យើងដាក់ក្រោយ ។

វណ្ណៈ ចឹងនៅហ្នឹងយ៉ាងម៉េចបានដាក់ភូមិពេជ្រចិន្តា?

ឯម: មិនដឹងយ៉ាងម៉េចអ្នកធំៗគាត់ដាក់ឈ្មោះពេជ្រចិន្តា មានអូរពេជ្រចិន្តាត្រង់ណានោះ ។

វណ្ណៈ ចឹង?

ឯម: ចាស!ដល់ចឹងដាក់ភូមិពេជ្រចិន្តាទៅ ។

វណ្ណៈ ចឹងនៅខាងក្រោយនេះមានអូរមានអីទេ?

ឯម: មានអូរព្រំដែន ។

វណ្ណៈ ចឹងអូរព្រំដែនហ្នឹងឆ្ងាយទេ?

ឯម: ឆ្ងាយណាស់ ។

វណ្ណៈ ចឹងយើងទៅធ្វើចំការអីជិតចំការរបស់ថៃដែរ?

ឯម: ចាស ។

វណ្ណៈ ដែលជួបពួកថៃប្រជាជនថៃអីទេ?

ឯម: ខ្ញុំអត់បានដឹងទេ ព្រោះចំការខ្ញុំអត់ទៅខាងហ្នឹងផង ចំការខ្ញុំទៅខាងនេះវិញ មានគេខាងនោះចំការគេនៅជាប់អូរចឹងទៅ តែមិនដែលឃើញថៃផង ។

វណ្ណៈ ចឹងមីងគិតថា ការរស់នៅសម័យគស្ទីឬសម័យបច្ចុប្បន្ននេះមីងគិតថាសម័យណាល្អជាងស្រួលជាង?

ឯមៈ	សម័យយើងនេះហើយស្រួលជាង ជួបជុំគ្រួសារទាំងអស់ទាំងកូនទាំងចៅយើង ។

វណ្ណៈ	បាទ ។

ឯមៈ	បានសប្បាយ ។

វណ្ណៈ	យើងរកបានប៉ុន្មានយកប៉ុណ្ណឹង?

ឯមៈ	ចាស ។

វណ្ណៈ	តែមានអ្នកខ្លះនិយាយថាសម័យតស៊ូគេមិនបានខ្វាយខ្វល់រឿងអត់បាយអីទេឲ្យតែធ្វើការបានហូបអីគ្រប់គ្រាន់យ៉ាងម៉េចដែលគេគិតចឹង?

ឯមៈ	មិនដឹងយ៉ាងម៉េចទេ អាហ្នឹងវាមហ្សាង ។

វណ្ណៈ	ចឹងចំពោះមីងវិញគិតថាពីមុនស្រួលជាងឬឥឡូវស្រួលជាង?

ឯមៈ	ឥឡូវស្រួលជាង ។

វណ្ណៈ	ចឹងមីងមានដីស្រែច្រើនដែរ?

ឯមៈ	អត់ខ្ញុំចាប់បានដីបន្តិច បានដីចំការ ។

វណ្ណៈ	នៅប្រជាជនភាគច្រើនដាំដំណាំអីជាប្រចាំ?

ឯមៈ	ឥឡូវគេដាំបីមុខដាំដំឡូង សណ្តែក ពោត តែឆ្នាំនេះពោតមិនសូវមានទេ ។

វណ្ណៈ	ពោតមិនសូវមានទេ?

ឯមៈ	ចាស!គេដាំដំឡូងច្រើន ។

វណ្ណៈ	ព្រោះដំឡូងបានថ្លៃ?

ឯមៈ	ចាស!ឆ្នាំទៅបានថ្លៃរបស់គេ ។

វណ្ណៈ	ចឹងពោតមិនសូវបានថ្លៃទេ?

ឯមៈ	ពោតទោះបីឡើងថ្លៃក៏មិនឈ្នះដំឡូងដែរ ។

វណ្ណៈ	ចឹងដំឡូងបានធូន់ជាងឬមួយយ៉ាងម៉េច?

ឯមៈ	ធូន់ជាងដំឡូងក្នុងមួយរ៉ៃបាន១០០០០បាត ពោតមួយរ៉ៃមិនបាន១០០០០ទេ ។

វណ្ណៈ	បាទ ។

ឯមៈ	២០០០ទៅ៣០០០ហ្នឹងឯង ដំឡូងបានច្រើនឆ្នាំនេះបានមួយម៉ឺនជាងនោះមួយម៉ឺនប្រាំនិងដំឡូងល្អ ។

វណ្ណៈ	បាទ ។

ឯមៈ	ហើយពោតទោះបីជាល្អយ៉ាងម៉េចក៏អត់បានដែរ បានអស់ហើយបួនទៅប្រាំពាន់ ។

វណ្ណៈ ចឹងដល់ពេលដាំដំណាំបានចឹងដីបានថ្ងៃទៀតហើយ?

ឯមៈ ដីឡើងតែមានពីណាទិញស្ងប់ត្រឹមហ្នឹងហើយ ស្ងប់ឈឺងរឿងដី ឥឡូវដីលក់ដីចំការមួយរ៉ៃមួយម៉ឺនជាង១២០០០បាត ។

វណ្ណៈ បាទ ។

ឯមៈ អាហ្នឹងចូលចំការក្នុងៗ ។

វណ្ណៈ ចឹងចំការជាប់ថ្នល់នេះ?

ឯមៈ ជាប់ថ្នល់នេះមិនបានទេ ថ្លៃណាស់ ។

វណ្ណៈ ចឹងមីងកាលហ្នឹងមិនទៅខាងសំឡូតខាងម៉ាឡៃអីទេ?

ឯមៈ អត់ផង ។

វណ្ណៈ ចឹងមីងជំនារខាងនេះ?

ឯមៈ ចាស!ខ្ញុំចូលមកចុះពីកំរៀងមកនៅតាមហ្នឹងរហូតអត់មានទៅណាទេ ។

វណ្ណៈ ចឹងនៅក្រោយសម័យក្រោយ៧៩មានដែលឃើញតា ប៉ុល ពត តា អៀង សារីមកហ្នឹងទេ?

ឯមៈ អត់មកទេ មិនដែលឃើញផង ។

វណ្ណៈ មិនដែលឃើញទេ?

ឯមៈ ចាស ។

វណ្ណៈ ចឹងកាលសម័យសង្គ្រាមនិងមានដាច់ដៃដាច់ជើងច្រើនគ្នាដែលមីង?

ឯមៈ មាន របួសពិការដៃពិការជើង ។

វណ្ណៈ ចឹងមីងគិតថាសង្គ្រាមកន្លងមកបានធ្វើឲ្យប៉ះពាល់អារម្មណ៍និងអាយុជីវិតមនុស្សយ៉ាងម៉េចដែរ ហើយវាខាតប្រយោជន៍អីខ្លះដែរ បើតាមយោបល់មីងគិតមើល?

ឯមៈ សង្គ្រាមវាប៉ះពាល់ហើយ ប៉ះពាល់ដល់ប្រជាពលរដ្ឋដាច់ដៃដាច់ជើងខ្លះ បែកបាក់គ្រួសារទៅ មានស្លាប់មានអីចឹងទៅណាស់ ។

វណ្ណៈ ចឹងមីងគិតថាមេដឹកនាំជំនាន់ខ្មែរក្រហមធ្វើនិងវាខុសឆ្គងឬមិនខុសឆ្គងទេ ចំពោះប្រជាជនមកលើប្រជាជន?

ឯមៈ ពិបាកណាស់ បើគាត់ដឹកនាំមកពួកខ្ញុំដូចជាមិនអី ។

វណ្ណៈ បាទ ។

ឯមៈ ទៅផ្សេងចឹងទៅវាខុសគ្នា ។

វណ្ណៈ	បាទ ។

ឯម:	ដូចថាក្រសួងផ្សេងៗហ្នឹងវាខុសៗគ្នា ។

វណ្ណៈ	ចឹងមីងគិតថាមនុស្សអត់បាយនិងស្លាប់នៅជំនាន់ហ្នឹងមីងជឿថាមានចឹងមែនដែលអត់?

ឯម:	ជឿដែលហ្នឹងឯង ។

វណ្ណៈ	មីងជឿ?

ឯម:	ចាស ។

វណ្ណៈ	ចឹងកាលគេសម្លាប់ សុន សេន សម្លាប់០៦អីហ្នឹងមីងមានដឹងទេកាលហ្នឹង?

ឯម:	ខ្ញុំដឹងតាមគេដែលហ្នឹង ។

វណ្ណៈ	ចឹងមីងមានដឹងហេតុអីបានជាខ្មែរក្រហមសម្លាប់គ្នាឯង ដឹងមូលហេតុទេ?

ឯម:	អត់ដឹង អត់ដឹងទាល់រាល់ថ្ងៃហ្នឹងឯង ។

វណ្ណៈ	ចឹងរាល់ថ្ងៃហ្នឹងមីងមានដែលបានស្តាប់រឿងតុលាការកាត់ទោសឌុចជាមេគុកទួលស្លែងទេ មីងមានដែលបានស្តាប់ទេ?

ឯម:	ស្តាប់ដែរ ។

វណ្ណៈ	មីងយល់ថាម៉េចដែរ?

ឯម:	ពិបាកថាណាស់ ។

វណ្ណៈ	ចឹងមីងគិតថាតុលាការដែលកាត់ទោសមេដឹកនាំខ្មែរក្រហមសព្វថ្ងៃហ្នឹងតុលាការធ្វើចឹងត្រឹមត្រូវឬមួយមិនត្រឹមត្រូវទេ នេះជាចិត្តរបស់មីងគិតមិនអីទេ?

ឯម:	ត្រឹមត្រូវហ្នឹងហើយតាមច្បាប់គេចែងមក គេកាត់ធ្វើតាមហ្នឹងត្រឹមត្រូវហើយគេធ្វើតាមច្បាប់និងហើយ ។

វណ្ណៈ	បាទ ។

ឯម:	យើងម៉េចធ្វើខុសច្បាប់កើត ។

វណ្ណៈ	បាទ ។

ឯម:	ច្បាប់អនុវត្តន៍ដាក់មកហើយ យើងត្រូវធ្វើតាមច្បាប់ ច្បាប់និងត្រឹមត្រូវហើយ ។

វណ្ណៈ	ចឹងអ្នកដឹកនាំគេធ្វើឲ្យប្រជាជនមានគ្រោះថ្នាក់ច្រើនត្រូវតែមានទោស?

ឯម:	ចាស ។

វណ្ណៈ	មីងធ្លាប់ទៅលេងស្រុកកំណើតបានប៉ុន្មានដង?

ឯម:	បានទៅច្រើនដងដែលហ្នឹងតែខានពីរឆ្នាំនេះមិនបានទៅ រវល់ ។

វណ្ណៈ ចឹងមីងបានទៅមើលទឹកដីស្រុកកំណើតនិងមីងចង់ទៅរកនៅហ្នឹងឬមិនចង់រស់នៅទេឬចង់រស់នៅនេះជាង?

ឯមៈ ចង់រស់នៅនេះជាង ។

វណ្ណៈ ហេតុអីទៅ?

ឯមៈ ព្រោះយើងមានដីយើងនៅនេះ ។

វណ្ណៈ បាទ ។

ឯមៈ នៅនោះអត់មានដី បើនៅពឹងដោយសារបងអីអត់កើត ។

វណ្ណៈ ចឹងមីងមានកូនចៅធំៗអស់ហើយមានរៀបការហើយនៅ?

ឯមៈ មានរៀបការមួយនៅមួយ ។

វណ្ណៈ នៅរៀនដែរ?

ឯមៈ ឈប់ហើយឥឡូវ ។

វណ្ណៈ ឈប់រៀនហើយ?

ឯមៈ ចាស ។

វណ្ណៈ ចឹងមីងនៅនេះបោះទីតាំងតែម្ដងនៅឆ្នាំណាមីងមានចាំទេ?

ឯមៈ មកនៅនេះ ។

វណ្ណៈ បាទ ។

ឯមៈ មកនៅនេះឆ្នាំ៩៥ ។

វណ្ណៈ ចឹងឆ្នាំ៩៥ បានមកនៅ?

ឯមៈ ចាស ។

វណ្ណៈ ជិតសមាហរណ៍កម្មហើយហ្នឹង?

ឯមៈ ចាស ។

វណ្ណៈ ចឹងមុនហ្នឹងមីងនៅណា?

ឯមៈ មុនខ្ញុំនៅអូរអន្លក់ ខ្ញុំនៅភ្នំភ្លើងឆេះ តែខ្ញុំនៅក្នុងដីថៃទាំងអស់ ។

វណ្ណៈ អត់ហ៊ានចូលទីនេះទេ?

ឯមៈ អត់ហ៊ាននៅដីយើងទេ នៅដីយើងតែទ័ពទេ ។

វណ្ណៈ ចឹងក្រោយចរចាគ្នាហើយបាននាំគ្នាមកនៅទីនេះ?

ឯមៈ ចាស ។

វណ្ណៈ នាំគ្នាកាប់ព្រៃអីចឹងទៅយកដីអីចឹងទៅ?

ឯមៈ ចាស ។

វណ្ណៈ ពីកាប់កាប់បានច្រើនយកច្រើនទៅឬមួយគេចែក?

ឯមៈ គេចែកបួនក្បាល៤០ បណ្ដោយស្រោចតែយើងកាប់ទៅ យើងកាប់ដល់ណាកាប់ទៅ ។

វណ្ណៈ បាទ ។

ឯមៈ ចេះតែទៅ ។

វណ្ណៈ ចឹងមីងបាន៤០កាប់ទៅក្រោយចេះ?

ឯមៈ ចាស!កាប់ទៅក្រោយដល់ត្រឹមមីននោះ ចោលត្រឹមហ្នឹង ។

វណ្ណៈ ចឹងម៉េចដឹងថាមានមីន?

ឯមៈ ចុះបន្ទាយយួន ។

វណ្ណៈ ចឹង?

ឯមៈ ចាស ។

វណ្ណៈ ឥឡូវគេដោះអស់ឬនៅ?

ឯមៈ ដោះអស់ហើយ ។

វណ្ណៈ ដោះហើយកាប់ទៀត?

ឯមៈ ដោះហើយគេយកដីហ្នឹង ព្រោះបន្ទាយនិងធំ គេយកដីហ្នឹងធ្វើដីភូមិចែកប្រជាពលរដ្ឋនៅ ៦០គ្រួសារហ្នឹង ។

វណ្ណៈ ខាងក្រោយនិង?

ឯមៈ ចាស!ដីហៅភូមិថ្មី ភូមិពេជ្រចិន្តានិងតែកើតភូមិថ្មីចឹង ។

វណ្ណៈ ចឹងឥឡូវមានប្រជាជនមកពីក្នុងមករស់នៅនិងមានទេមីង?

ឯមៈ មានសុទ្ធតែអ្នកក្នុង ។

វណ្ណៈ រស់នៅហ្នឹងទៅ?

ឯមៈ ចាស!ចែកឲ្យមួយបួនៗម្នាក់ទៅ ។

វណ្ណៈ ចែកឬក៏ទិញ?

ឯមៈ ចែកអត់មានលក់ទេ ។

វណ្ណៈ គាត់មកយូរដែលហើយចឹង?

ឯមៈ គាត់មកយូរហើយខ្លះ បួនប្រាំឆ្នាំហើយ ។

វណ្ណៈ ចឹងពេលមកឥឡូវទាល់តែទិញ?

ឯមៈ មកឥឡូវអត់មានអីចែក គេចែកតែអ្នកមកយូរនិងអស់ហើយ ។

វណ្ណៈ តែបើវចង់មកទាល់តែទិញ?

ឯមៈ ចាស!ទាល់តែទិញ ។

វណ្ណៈ ចឹងដំណាំដែលប្រជាជនធ្វើបាននិងយកទៅខាងណាវិញ?

ឯមៈ យកទៅថៃភាគច្រើន ។

វណ្ណៈ ចឹងអត់មានអ្នកជំនួញខាងក្នុងគេមកទិញទេ?

ឯមៈ មកដែលពោតអីថាទិញៗចឹងទៅមួយដើងបាត់ឈឹងទៅ ដំឡូងអីហ្នឹង ។

វណ្ណៈ បាទ ។

ឯមៈ ដល់ចឹងគេចង់លក់ឲ្យថៃលឿនជាង ស្តុបទុកយូរវាខូចណាស់ ។

វណ្ណៈ បាទ ។

ឯមៈ ម្លោះហើយលក់ឲ្យថៃលឿន ។

វណ្ណៈ ចឹងដូចជាគ្រឿងអីហ្នឹងយើងយកមកពីថៃដែរ?

ឯមៈ គ្រឿងមកពីថៃ ។

វណ្ណៈ មានយូរហើយឬទើបតែមានទេ?

ឯមៈ មានប៉ុន្មានឆ្នាំហើយទេ វាមិនបានចាប់អារម្មណ៍ដែរ ។

វណ្ណៈ គេទិញតពីថៃមកដែរ?

ឯមៈ ចាស!គាត់ទិញតពីថៃ គាត់ក្រុមហ៊ុន ។

វណ្ណៈ ចឹងមីងមកកាលហ្នឹងមីងមានឃើញដើមឈើធំៗច្រើនទេ?

ឯមៈ ចាស!មានច្រើនពេញហ្នឹងតូ កាប់ដុតចោលមើលអីចឹង កាលហ្នឹងពីណាគេមានម៉ាស៊ីនគេកាត់ម៉ាស៊ីនទៅ យើងអត់មានម៉ាស៊ីនយើងកាប់ដៃទៅ ។

វណ្ណៈ ចឹងយើងមានកាប់លក់អីខ្លះបានទេ?

ឯមៈ អត់ទេ កាប់លក់ដីងពីណាគេទិញផង បើបេងមានគេទិញ ។

វណ្ណៈ បាទ ។

ឯមៈ បើបេងអាលក់ទៅ បើអត់បេងកាប់ដុតៗណាត្រូវទុកអាឈើទុកទៅមិនត្រូវទុកកាប់ខ្ទិច ។

វណ្ណៈ ចឹងអ្នកជំនាន់ក្រោយចង់ធ្វើផ្ទះឈើទៀតអត់មានទេ?

ឯមៈ អត់មានទេ ឈើថ្លៃណាស់ឥឡូវហើយមិនមានទៀតណាស់ មានសុទ្ធមិនព្យាបាលទៀតឈើឥឡូវ ។

វណ្ណៈ បាទ ។

ឯមៈ មើលមុនសុទ្ធតែគគីរសុទ្ធតែអី ។

វណ្ណៈ ចឹងខ្ញុំដូចជាអស់អីសួរមីងហើយមីងមានអីចង់និយាយទៀតទេ?

ឯមៈ អត់មានទេ ។

វណ្ណៈ ចឹងខ្ញុំអរគុណមីងច្រើនហើយ ។

ឯមៈ ចាស ។

**ចប់**